

# អបអរសាទរ ទិវាបុណ្យជាតិជប៉ុន

# លើកកម្ពស់ទំនាក់ទំនងដ៏សម្បូរបែបនិងចម្រុះ រវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា

ជម្រាបសួរ! ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែងដែលបានប្រារព្ធទិវាបុណ្យជាតិជប៉ុន ជាមួយប្រជាជនកម្ពុជាសាជាថ្មីម្តងទៀតនៅឆ្នាំនេះ។

ខ្ញុំធ្លាប់បានមករាជធានីភ្នំពេញលើកទី១ ក្នុងឆ្នាំ២០០២ ដើម្បីអមដំណើរនាយករដ្ឋមន្ត្រីពេលនោះ ឯកឧត្តម កូអ៊ិហ្សឹមិ ជូនអ៊ិឈិរ៉ូ( KOIZUMI Junichiro ) ចូលរួមកិច្ចប្រជុំកំពូលពាក់ព័ន្ធនឹងអាស៊ាន។ ២០ឆ្នាំក្រោយមក ខ្ញុំរីករាយណាស់ដែលបានវិលមកបំពេញការងារ ជាមួយមិត្តកម្ពុជា ដើម្បីសម្រេចបាននូវជោគជ័យនៃកិច្ចប្រជុំនានាពាក់ព័ន្ធនឹងអាស៊ានម្តងទៀត។ បច្ចុប្បន្ន អាស៊ាន កំពុងប្រឈមបញ្ហាផ្សេងៗ ប៉ុន្តែខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កម្ពុជានឹងដឹកនាំអាស៊ានប្រកបដោយភាពឈ្លាសវៃក្នុងអំឡុងពេលធ្វើជាប្រធាន។ ជប៉ុននឹងជួយដល់ការខិតខំប្រឹងប្រែងរបស់កម្ពុជា។

ឆ្នាំនេះ ជាខួបលើកទី៣០នៃប្រតិបត្តិការថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ (PKO) នៅកម្ពុជា។ បន្ទាប់ពីការសម្រេចបាននៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិ (UNTAC) បានចាប់ផ្តើមប្រតិបត្តិការក្នុងឆ្នាំ១៩៩២ ដែលដឹកនាំដោយលោក អាកាស៊ិ យ៉ាស៊ូស៊ិ (AKASHI Yasushi)។ កម្ពុជា គឺជាប្រទេសដំបូងដែលជប៉ុនបានបញ្ជូនក្រុមប្រតិបត្តិការថែរក្សាសន្តិភាពរបស់ខ្លួនមកបេសកកម្ម PKO។ យើងពិតជាមានមោទនភាពខ្លាំង ដែលប្រទេសជប៉ុនបានរួមចំណែកយ៉ាងសំខាន់ ក្នុងដំណើរការកសាងសន្តិភាព ព្រមទាំងការស្តារឡើងវិញ និងអភិវឌ្ឍប្រទេសកម្ពុជាជាបន្តបន្ទាប់។ ពាក់ព័ន្ធនឹងចំណុចនេះ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រទេសកម្ពុជាចំពោះតួនាទីសកម្មនាពេលថ្មីៗនេះក្នុងការរួមចំណែកថែរក្សាសន្តិភាពក្នុងពិភពលោក តាមរយៈការបញ្ជូន ក្រុមកងកម្លាំងរបស់ខ្លួនទៅ PKOs។



ឯកឧត្តម មិកាមិ ម៉ាសាហ៊ីរ៉ូ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា។

នៅកម្ពុជា ដោយសារមានការខិតខំប្រឹងប្រែងដ៏ធំធេងរបស់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ស្ថានការណ៍នៃកូវីដ១៩ ស្ថិតនៅក្រោមការគ្រប់គ្រងក៏ពិតមែន ប៉ុន្តែនៅតែមិនអាចស្មានទុកជាមុនបាន។ រដ្ឋាភិបាលជប៉ុនបាននិងកំពុងផ្តល់ជំនួយគ្រប់រូបភាពដល់កម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ ដូចជា ការផ្តល់ជំនួយវ៉ាក់សាំងប្រភេទ AstraZeneca ប្រមាណ ១,៣លានដូស ដែលផលិតនៅប្រទេសជប៉ុន។ ប្រទេសជប៉ុនក៏បានផ្តល់រថយន្តគិលានសង្គ្រោះ ១០០គ្រឿង និងសម្ភារ បរិក្ខារពេទ្យ ដូចជា ឧបករណ៍រក្សាភាពត្រជាក់ ព្រមទាំងបាននិងកំពុងជួសជុលមន្ទីរពេទ្យ និងជួយសម្រួលដល់ការវិលត្រឡប់របស់ពលករចំណាកស្រុក ដោយកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ។ ប្រទេសជប៉ុនក៏នឹងបន្ថែមប្រាក់កម្ចីយ៉េនរហូតដល់ប្រមាណជា១៨៥លានដុល្លារអាមេរិក បន្ថែមលើទឹកប្រាក់ចំនួន ២២៧លានដុល្លារអាមេរិក ដែលត្រូវបានបញ្ចេញកាលពីខែមករា ឆ្នាំ២០២១។ នេះគឺត្រូវបានធ្វើឡើងដើម្បីជួយទប់ស្កាត់ការរីករាលដាលនៃកូវីដ១៩ និងដើម្បីស្តារឡើងវិញ និងថែរក្សាសកម្មភាពសេដ្ឋកិច្ច និងសង្គម ព្រមទាំងជួយសម្រួលដល់ការរស់នៅរបស់ជនងាយរងគ្រោះ។

ប្រទេសជប៉ុន បាននិងកំពុងអនុវត្តគម្រោងផ្សេងៗ ដើម្បីគាំទ្រដល់ការលើកកម្ពស់គុណភាពជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា រួមមាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយធំនៅទីតាំងដូចជា កំពង់ផែក្រុងព្រះសីហនុ និងផ្លូវជាតិលេខ៥។ ថ្មីៗនេះ ប្រទេសជប៉ុនក៏ជួយដល់គំនិតផ្តួចផ្តើមរបស់កម្ពុជាក្នុងការសម្រេចបាននូវឧស្សាហកម្ម ៤.0 តាមរយៈការផ្តល់នូវបច្ចេកវិទ្យាទំនើប រួមទាំងបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍( ICT ) ផងដែរ។ ជាឧទាហរណ៍ យើងបានសម្រេចផ្តល់ឧបករណ៍វាស់វែងតាម GPS ដែលមានលក្ខណពិសេស និងម៉ាស៊ីនត្រួតពិនិត្យលេខ កុំព្យូទ័រ (CNC) ដែលទំនើបបំផុតដល់កម្ពុជា។ យើងក៏ផ្តល់ជំនួយជាច្រើនដែលផ្តោតលើសហគមន៍ ក្នុងវិស័យអប់រំ សុខាភិបាល និងទឹកអនាម័យ តាមរយៈ «ជំនួយឥតសំណងរបស់ជប៉ុនសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណេ)»និងគម្រោងផ្សេងទៀត។

ទំនាក់ទំនងសេដ្ឋកិច្ច រួមទាំងពាណិជ្ជកម្ម និងការវិនិយោគរវាងកម្ពុជា និងជប៉ុន ក៏មានការរីកចម្រើនជាលំដាប់។ បច្ចុប្បន្នមានក្រុមហ៊ុនជប៉ុនជាង ៣០០ កំពុងប្រតិបត្តិការនៅកម្ពុជា។ ផ្សារទំនើប AEON Mall ទី ៣ គ្រោងនឹងបើកដំណើរការនៅឆ្នាំ ២០២៣។ សម្រាប់ការធ្វើឱ្យប្រសើរឡើងបន្ថែមទៀតនៃបរិយាកាសវិនិយោគ សមាគមធុរកិច្ចជប៉ុននៅកម្ពុជា (JBAC) កំពុងធ្វើការយ៉ាងសកម្មជាមួយរដ្ឋាភិបាលកម្ពុជា តាមរយៈក្របខ័ណ្ឌនៃកិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា-ជប៉ុន ដែលខ្ញុំធ្វើជាប្រធានជាមួយ ឯកឧត្តម សុខ ចិន្តាសោភា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

នៅក្នុងវិស័យវប្បធម៌ និងកីឡា មហោស្រពគីហ្សូណាជប៉ុន-កម្ពុជា ២០២២ ដែលជាព្រឹត្តិការណ៍វប្បធម៌ជប៉ុនដ៏ធំបំផុតមួយនៅកម្ពុជា ទើបតែត្រូវបានប្រារព្ធឡើងកាលពីសប្តាហ៍មុន។ ឆ្នាំនេះ យើងអាចប្រារព្ធមហោស្រពនេះឡើងក្នុងទម្រង់ចម្រុះ ដែលមាននៅទីតាំងផ្ទាល់ខ្លះ និងតាមអនឡាញខ្លះ។ ទាក់ទងនឹងបេតិកភណ្ឌបុរាណអង្គរនៅកម្ពុជា ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលរដ្ឋាភិបាលជប៉ុន និងស្ថាប័នសិក្សារបស់ជប៉ុនបាននិងកំពុងចូលរួមចំណែកក្នុងការស្រាវជ្រាវ អភិរក្ស និងជួសជុល ជាច្រើនឆ្នាំមកហើយ។

ជនជាតិជប៉ុនជាច្រើននាក់ក៏កំពុងជួយដល់ការអភិវឌ្ឍកីឡាដែរ។ ជាឧទាហរណ៍កីឡាករបាល់ទាត់ដ៏ល្បី ១រូប គឺលោក ហុងដា កេស៊ឹកិ (HONDA Keisuke) ជាអ្នកគ្រប់គ្រងទូទៅនៃក្រុមបាល់ទាត់ជម្រើសជាតិកម្ពុជា។ បន្ថែមពីនេះ ស្ថាប័នថ្មីមួយសម្រាប់ការលើកកម្ពស់លីគបាល់ទាត់អាជីពក៏ត្រូវបានបង្កើតឡើងថ្មីៗនេះ ហើយនាយកប្រតិបត្តិនៃស្ថាប័ននេះ ក៏ជាអ្នកជំនាញជប៉ុនដែលមានបទពិសោធផងដែរ។ កីឡាករបាល់ទាត់វ័យក្មេងរបស់ជប៉ុនកំពុងចូលរួមក្នុងក្លិបបាល់ទាត់កម្ពុជា។ ខ្ញុំជឿថា កីឡាបាល់ទាត់គឺពិតជាមានថាមពលក្នុងការបង្រួបបង្រួមប្រជាជនប្រកបដោយភាពរីករាយ ហើយការបង្កើនសមត្ថភាពកីឡាបាល់ទាត់របស់កម្ពុជានឹងរួមចំណែកជួយលើកកម្ពស់កម្រិតទាំងមូលនៃបាល់ទាត់នៅអាស៊ី។

កត្តាខាងលើនេះគ្រាន់តែជាទិដ្ឋភាពមួយចំនួននៃទំនាក់ទំនងដ៏សម្បូរបែប និងចម្រុះរវាងប្រទេសយើងទាំង ២ប៉ុណ្ណោះ។ ឆ្នាំក្រោយនឹងប្រារព្ធខួបលើកទី ៧០ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសជប៉ុននិងកម្ពុជា។ ខ្ញុំចង់ធ្វើការជាមួយរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដើម្បីលើកកម្ពស់បន្ថែមទៀតនូវភាពជាដៃគូយុទ្ធសាស្ត្រ ដែលត្រូវបានបង្កើតឡើងដោយនាយករដ្ឋមន្ត្រីទាំង២របស់យើងក្នុងឆ្នាំ២០១៣។

ក្នុងឱកាសនៃទិវាបុណ្យជាតិជប៉ុននេះ ទូលបង្គំ សូមថ្វាយព្រះពរ ព្រះករុណា ព្រះចៅអធិរាជ និងព្រះអធិរាជិនីជប៉ុន ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះករុណា ព្រះមហាក្សត្រ ព្រះមហាក្សត្រីព្រះវររាជមាតាជាតិ និងសូមជូនពរប្រជាជនកម្ពុជា និងជប៉ុន សូមមានសុខភាពល្អ សុភមង្គល និងវិបុលភាព។ ខ្ញុំក៏សូមជូនពរឱ្យចំណងមិត្តភាពរវាងជប៉ុន និងកម្ពុជា បន្តរីកចម្រើនជានិច្ចនិរន្តរ៍។ ■

# ជប៉ុនអនុវត្តគម្រោងជោគជ័យជាច្រើនសម្រាប់ប្រជាពលរដ្ឋ

គំនិតផ្តួចផ្តើមរបស់ជប៉ុនក្នុងការធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពរបស់សហគមន៍មូលដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជានៅតែបន្តឥតឈប់ឈរ ទោះបីដំណើរការអស់២ទសវត្សរ៍ហើយក្តី។ ជំនួយឥតសំណងនេះគឺសម្រាប់គម្រោងនៅថ្នាក់មូលដ្ឋាន ដើម្បីជំរុញការអភិវឌ្ឍ និងបំពេញតម្រូវការរបស់ប្រជាពលរដ្ឋមូលដ្ឋានជាពិសេសនៅតំបន់ជនបទ។

រដ្ឋាភិបាលជប៉ុនបានឯកភាពផ្តល់ថវិកាចំនួន ៧២៨ ៥០១ដុល្លារអាមេរិកដល់អង្គភាពទទួលជំនួយចំនួន ៣ ក្រោមគ្រោងការជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ដើម្បីអនុវត្តគម្រោងនៅថ្នាក់មូលដ្ឋាន។

ឯកឧត្តម មិកាមិ ម៉ាសាហ៊ីរ៉ូ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសជប៉ុនប្រចាំកម្ពុជា និងអ្នកតំណាងអង្គភាពទទួលជំនួយទាំង៣ បានចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយកាលពីខែមករា កន្លងទៅ។

គម្រោងសំខាន់ៗទាំងនោះរួមមាន «គម្រោងពង្រឹងប្រព័ន្ធវេជ្ជសាស្ត្រដើម្បីអនុវត្តការវះកាត់កុមារ»នៅក្នុងខេត្តក្រចេះ ដែលទទួលថវិកាចំនួន ១២៥ ០១២ដុល្លារអាមេរិក សម្រាប់រយៈពេល៣ឆ្នាំ។



ឯកឧត្តម មិកាមិ ម៉ាសាហ៊ីរ៉ូ (រូបទី៤ រាប់ពីស្តាំ)នៅក្នុងពិធីចុះហត្ថលេខាផ្តល់ជំនួយ។

អង្គភាពទទួលជំនួយ គឺអង្គការមូលនិធិសម្រាប់ការអភិវឌ្ឍនិងជំនួយសង្គ្រោះអន្តរជាតិ ដែលជួយពង្រឹងប្រព័ន្ធថែទាំផ្នែកវះកាត់កុមារក្នុងខេត្តក្រចេះ តាមរយៈការបណ្តុះបណ្តាលដល់បុគ្គលិកពេទ្យនៃមន្ទីរពេទ្យបង្អែកខេត្ត មណ្ឌលសុខភាព និងអ្នកស្ម័គ្រចិត្តសុខភាពភូមិ ដើម្បីកែលម្អគុណភាពនៃការអនុវត្តការវះកាត់ និងពង្រឹងបណ្តាញដឹកជញ្ជូនអ្នកជំងឺក្នុងខេត្តក្រចេះ និងបង្កើនការយល់ដឹងអំពីការថែទាំវេជ្ជសាស្ត្រក្នុងសហគមន៍។

ឯកឧត្តម មិកាមិ ម៉ាសាហ៊ីរ៉ូ បានថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ នាថ្ងៃទី១៩ ខែមករាថា៖«នៅពេលខ្ញុំបានឃើញភាពស្អាតនៃបរិក្ខារនោះ និងអ្នកជំងឺដែលកំពុងសម្រាកព្យាបាលនៅទីនោះ ខ្ញុំមានអារម្មណ៍ថា វាជាការគាំទ្រដ៏ល្អ និងមានអត្ថន័យ»។

«ខ្ញុំសូមគោរពកោតសរសើរចំពោះសកម្មភាពនានារបស់អង្គការ អស់រយៈពេលជាច្រើនឆ្នាំមកនេះ។ នៅក្នុងឆ្នាំទី៣ នៃការអនុវត្តគម្រោងនេះ អង្គការនឹងបន្តសកម្មភាពបណ្តុះបណ្តាលបុគ្គលិកមន្ទីរពេទ្យខេត្ត ដែលបានចាប់ផ្តើមតាំងពីឆ្នាំទី១ ហើយគ្រោងនឹងអនុវត្តសកម្មភាពនានាដើម្បីពង្រឹងប្រព័ន្ធដឹកជញ្ជូនអ្នកជំងឺក្នុងខេត្ត និងផ្សព្វផ្សាយចំណេះដឹងផ្នែកវេជ្ជសាស្ត្រដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។ ខ្ញុំសង្ឃឹមថាតាមរយៈគម្រោងនេះ កុមារនៅពេលអនាគតនឹងអាចទទួលបានការព្យាបាលសមស្រប និងឆាប់រហ័ស»។

ចំពោះគម្រោងទី២គឺគម្រោងពង្រឹងការថែទាំសុខភាពសហគមន៍ និងបណ្តាញគាំទ្រសម្រាប់កុមារក្នុងខេត្តកំពង់ចាម ហើយអង្គភាពទទួលជំនួយគឺអង្គការមូលនិធិជប៉ុន (PHJ) ដែលទទួលបានថវិកាចំនួន ២០០ ៩០៦ ដុល្លារ សម្រាប់រយៈពេលជាង៣ឆ្នាំ។

នៅក្នុងគម្រោងនេះ អង្គការ PHJ មានគោលបំណងកាត់បន្ថយអត្រាមរណភាពកុមារអាយុក្រោម ៥ឆ្នាំ និងលើកកម្ពស់ការលូតលាស់ប្រកបដោយសុខភាពល្អរបស់កុមារ។ អង្គការនឹងបន្តគាំទ្រដល់ការបណ្តុះបណ្តាលចំណេះដឹងដល់បុគ្គលិកពេទ្យ និងអ្នកស្ម័គ្រចិត្តសុខាភិបាល ក៏ដូចជាការពង្រីកបណ្តាញរបស់ខ្លួន ជាមួយអ្នកភូមិនៅក្នុងសហគមន៍ដើម្បីសម្រេចបាននូវគោលដៅរបស់ខ្លួន។

អង្គការ PHJ ក៏នឹងផ្តល់ការអប់រំផ្នែកអាហារូបត្ថម្ភ ជាមួយនឹងការបណ្តុះបណ្តាលផ្នែកធ្វើម្ហូប ដើម្បីបង្កើនចំណេះដឹងរបស់អ្នកភូមិដែលមានកូនតូចៗ ដោយកុមារអាយុក្រោម ៥ឆ្នាំ ចំនួន ៤ ៦៦៩នាក់នឹងទទួលបានអត្ថប្រយោជន៍។

ចំណែកឯគម្រោងទី៣ គឺគម្រោងធ្វើឱ្យប្រសើរឡើងនូវបរិស្ថានសិក្សាតាមរយៈការសាងសង់អគារសិក្សានៅតាមសាលាបឋមសិក្សាក្នុងខេត្តបាត់ដំបង ដែលនឹងត្រូវអនុវត្តដោយអង្គការសន្តិស្ម័គ្រចិត្ត ដែលនឹងទទួលបានថវិកាចំនួន ៤០២ ៥៨៣ដុល្លារអាមេរិក។

សម្រាប់គម្រោងនេះ អង្គការនឹងសាងសង់អគារសិក្សាដែលរួមមានបន្ទប់បណ្ណាល័យ បង្គន់អនាម័យ និងកន្លែងលាងដៃ១កន្លែង នៅសាលាបឋមសិក្សាចំនួន៣ ក្នុងខេត្តបាត់ដំបង ដើម្បីកែលម្អបរិស្ថានសិក្សា និងអនាម័យ។

ព័ត៌មានលម្អិតអានតទៅគេហទំព័រ
WWW.POSTKHMER.COM

## JBAC pivotal in shaping strong bilateral ties

The Japanese Business Association of Cambodia (JBAC) was established in 1992 with the primary aim of promoting Japanese companies in Cambodia, and developing economic activities between the two nations.

Made up of 260 Japanese companies, the members of JBAC are mostly involved in the manufacturing, construction, real estate, trade, transport, commerce, finance, insurance and services sectors.

All its members maintain high standards, and comply with Cambodian social norms and laws, adhering strictly to new regulations and labour laws.

JBAC recognises that the Cambodia-Japan public-private sector meeting – held in accordance with the Cambodia-Japan Investment Agreement – is an important opportunity to discuss about further improving the Kingdom's investment environment.

Meanwhile, the channel of dialogue with the Cambodian government has expanded in recent years, with greater opportunities existing for individual dialogue and discussions with relevant ministries and agencies, while JBAC's voice has been reflected in policymaking decisions.

While the Covid-19 outbreak impacted Japanese investments in Cambodia – with withdrawals and delays in investment decisions – thanks to the Cambodian government's persistent efforts, the number of JBAC members has decreased only slightly compared to previous years.

Existing companies are expanding their investments with confidence, which has become a tailwind for Japanese investors currently considering new investment opportunities.

JBAC, with the cooperation of the Embassy of Japan in Phnom Penh, the Japan International Cooperation Agency (JICA), the Japan External Trade Organisation (JETRO) and other Japanese government agencies, has played a pivotal role in expanding Cambodia's economic growth as a public-private unity.

JBAC continues to contribute to Cambodia's economic development by working on business developments that meet the social needs of Cambodians, with Japanese quality every time.

HAPPY JAPAN NATIONAL DAY!




JBAC カンボジア日本人商工会
Japanese Business Association of Cambodia

# ប្រវត្តិសាស្ត្រនៃការតាក់តែងក្រមរដ្ឋប្បវេណី ក្រមនីតិវិធី-រដ្ឋប្បវេណី និងខួបគម្រប់១០ឆ្នាំនៃការអនុវត្តក្រមរដ្ឋប្បវេណី




**ពិធីប្រកាសការអនុវត្ត ក្រមរដ្ឋប្បវេណី កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។** រូបថត Supplied

ប្រវត្តិនៃគម្រោងកិច្ចសហប្រតិបត្តិការផ្នែកច្បាប់មួយរបស់ JICA ជាមួយក្រសួងយុត្តិធម៌ បានចាប់ផ្ដើមដំណើរការក្នុងគោលដៅជួយជ្រោមជ្រែងនៅក្នុងកិច្ចការតាក់តែងសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី។ នៅក្នុងដំណើរការនៃការតាក់តែងសេចក្ដីព្រាងក្រមនេះ ត្រូវបានបង្កើតក្រុមការងារមួយក្នុងប្រទេសកម្ពុជា និងក្រុមការងារមួយមកពីប្រទេសជប៉ុន។

ចំពោះនីតិវិធីនៃការតាក់តែងក្រមទាំង២នេះ ក្រុមការងារនៃប្រទេសជប៉ុន ត្រូវបានបែងចែកទៅជាក្រុមដែលទទួលបន្ទុកក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី។ រីឯក្រុមការងារនៃប្រទេសកម្ពុជាវិញ ជំហានដំបូងគឺផ្ដល់ព័ត៌មានដែលពាក់ព័ន្ធនានាក្នុងស្រុកទៅឱ្យក្រុមការងារនៃប្រទេសជប៉ុនដើម្បីរៀបចំសេចក្ដីព្រាងដំបូងសម្រាប់ជាមូលដ្ឋានគ្រឹះ និងយកមកដាក់ពិភាក្សាជាមួយនឹងក្រុមការងារប្រទេសកម្ពុជា ដោយមានការបកប្រែពីភាសាជប៉ុនមកជាភាសាខ្មែរ។

នៅក្នុងការពិភាក្សានៃការរៀបចំក្រមទាំង២នេះ ខាងភាគីជប៉ុនគ្រាន់តែផ្ដល់មាតិកា ខ្លឹមសារសំខាន់ៗដែលជាមូលដ្ឋានគ្រឹះនៃសេចក្ដីព្រាងក្រមទាំង២នេះតែប៉ុណ្ណោះ ប៉ុន្ដែការសម្រេចទៅលើខ្លឹមសារនៃសេចក្ដីព្រាងក្រមទាំង២នេះគឺអាស្រ័យទៅលើការសម្រេចរបស់ភាគីកម្ពុជា។

ជាមួយគ្នានេះ ដើម្បីសម្រួលសម្រាប់កិច្ចពិភាក្សារវាងក្រុមការងារកម្ពុជា និងក្រុមការងារជប៉ុន ភាគីជប៉ុនបានបញ្ជូនជំនាញការជប៉ុនរយៈពេលវែងមកធ្វើជាទីប្រឹក្សាផ្នែកច្បាប់ ដើម្បីមកធ្វើការផ្ទាល់ជាមួយក្រសួងយុត្តិធម៌កម្ពុជា ព្រមទាំងធ្វើការបណ្ដុះបណ្ដាលនានា តាមរយៈសិក្ខាសាលាខ្នាតតូច និងខ្នាតធំជាច្រើន។

បន្ថែមពីនេះទៀត នៅក្នុងការពិភាក្សាសេចក្ដីព្រាងនៃក្រមទាំង២នេះ ត្រូវបានយកមកត្រួតពិនិត្យយ៉ាងលម្អិត មុននឹងធ្វើការសម្រេចថាតើត្រូវប្រើប្រាស់ពាក្យពេចន៍ខ្មែរណាមួយនៅក្នុងភាសាច្បាប់ឱ្យបានត្រឹមត្រូវ និងបែងចែកច្បាស់នៅក្នុងនីតិវិធី និងធ្វើការពិភាក្សាម្ដង១មាត្រាៗនៃសេចក្ដីព្រាងក្រមទាំង២នេះ។

ជាលទ្ធផល ក្រមរដ្ឋប្បវេណីត្រូវបានអនុម័តនៅឆ្នាំ២០០៧ និងក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានអនុម័តនៅឆ្នាំ២០០៦។ ក្រមនីតិវិធីរដ្ឋប្បវេណី បានដើរតួយ៉ាងសំខាន់នៅក្នុងការសម្រួលដល់នីតិវិធីនៃការអនុវត្តនៅក្នុងការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណី នៅតាមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់។

បន្ទាប់មក នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ប្រទេសកម្ពុជាបានចាប់ផ្ដើមអនុវត្តក្រមរដ្ឋប្បវេណី ដែលនេះគឺជាការបោះជំហានថ្មីមួយ ដែលប្រទេសកម្ពុជាមានបទប្បញ្ញត្តិសារជាតុលើវិស័យរដ្ឋប្បវេណី ដែលអាចឆ្លើយតបនិងដោះស្រាយនូវគ្រប់បញ្ហាដែលទាក់ទងនឹងសិទ្ធិនិងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងផ្នែករដ្ឋប្បវេណី។

ចំពោះទាំងនៅក្នុងការតាក់តែង និងនៅក្នុងការអនុវត្តនៃក្រមទាំង២នេះ គឺជៀសមិនផុតពីការជួបនូវការលំបាកឡើយ ប៉ុន្ដែផ្លូវណាដែលលំបាក រមែងនាំទៅកាន់ទីកន្លែងដែលមានទេសភាពស្អាត។ កន្លងមក នៅក្នុងការអនុវត្តក្រមទាំង២នេះ មានទស្សនៈខ្លះទទួលស្គាល់ថាក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ពិតជាមានលក្ខណៈទំនើបកម្មពិតមែន ប៉ុន្ដែក៏នៅមានទស្សនៈខ្លះទៀតបានរិះគន់ទៅលើការប្រើប្រាស់វាក្យសព្ទថ្មីៗនៅក្នុងក្រមទាំង២នេះ ដែលជាហេតុធ្វើឱ្យមានការពិបាកយល់ និងពិបាកក្នុងការអនុវត្តផងដែរ។

ទាក់ទិនទៅនឹងទស្សនៈរិះគន់នេះ លោកជំទាវ ចាន់ សុទ្ធាវី ជាអ្នកគ្រប់គ្រងគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌បច្ចុប្បន្ន និងជារដ្ឋលេខាធិការប្រចាំការដែលជាថ្នាក់ដឹកនាំជាន់ខ្ពស់ស្ដ្រីតែម្នាក់នៃក្រសួងយុត្តិធម៌ បានមានប្រសាសន៍លើកឡើងថា៖«បទប្បញ្ញត្តិដែលទាក់ទងនឹងវិស័យរដ្ឋប្បវេណី គឺជាបទប្បញ្ញត្តិដែលមានលក្ខណៈស្មុគស្មាញជាទីបំផុត ហេតុនេះបើយើងរៀបចំខ្លឹមសារនៃបទប្បញ្ញត្តិនីមួយៗ ព្រមទាំងការប្រើប្រាស់ពាក្យពេចន៍មិនច្បាស់លាស់ទេ អាចនឹងបង្កការលំបាកក្នុងការអនុវត្ត ហើយនឹងធ្វើឱ្យយើងមិនអាចញែកដាច់នៅក្នុងបទប្បញ្ញត្តិនីមួយៗ ឬ នៅក្នុងនីតិវិធីនីមួយៗដែលបញ្ញត្តនៅក្នុងច្បាប់ ដូច្នេះការប្រើប្រាស់ពាក្យពេចន៍ថ្មី វាមិនមែនជារឿងចម្លែកនោះទេ ដោយហេតុថាពាក្យពេចន៍ថ្មីៗទាំងនោះអាចមានលក្ខណៈថ្មីសម្រាប់កម្ពុជា ប៉ុន្ដែបើពិនិត្យមើលទៅលើច្បាប់របស់ប្រទេសផ្សេងៗវិញ ពាក្យទាំងនេះត្រូវបានប្រើប្រាស់នៅក្នុងនីតិកម្មនៃការតាក់តែងច្បាប់នៃប្រទេសមួយចំនួនដូចជាប្រទេសជប៉ុន ជាឧទាហរណ៍។

កត្តាដែលសំខាន់នៅក្នុងការរៀបចំច្បាប់ គឺត្រូវរៀបចំច្បាប់មួយដែលអាចដោះស្រាយនូវរាល់បញ្ហាពាក់ព័ន្ធនឹងវិស័យរដ្ឋប្បវេណី ក៏ដូចជាកិច្ចការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ»។

លោកជំទាវបានបន្ថែមទៀតថា៖ «មធ្យោបាយដើម្បីជម្នះនូវការលំបាកភាពស្មុគស្មាញ និងទស្សនៈរិះគន់ គឺយើងត្រូវប្រឹងប្រែងរួមគ្នា ព្រមទាំងខិតខំស្វែងយល់អំពីមូលហេតុ និងសារៈប្រយោជន៍នៃការប្រើប្រាស់ពាក្យពេចន៍ថ្មីៗទាំងនោះ ហើយត្រូវបង្កើនការផ្សព្វផ្សាយ ទាំងខ្លឹមសារនៃក្រមទាំង២ និងសារៈប្រយោជន៍នៃការប្រើប្រាស់ពាក្យពេចន៍ថ្មីៗទាំងនោះឱ្យបានទូលំទូលាយដល់អ្នកច្បាប់ និងសាធារណជនទូទៅ»។

ការពង្រឹងចំណេះដឹងលើក្រមទាំង២ពិតជាមានភាពខ្លាំងក្លា ប៉ុន្ដែនៅតែត្រូវការថាមពលប្រកបដោយភាពក្លៀវក្លាពីសំណាក់អ្នកប្រកបវិជ្ជាជីវៈច្បាប់ទាំងអស់ ដែលនឹងចូលរួមក្នុងការជ្រោមជ្រែងពលរដ្ឋខ្មែរទូទៅឱ្យស្វែងយល់ ថា តើច្បាប់និយាយពីអ្វី។

កិច្ចសហប្រតិបត្តិការនៃការអនុវត្ត «គម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌» នេះ បច្ចុប្បន្នឈានទៅដល់ការអនុវត្តគម្រោងនៅក្នុងដំណាក់កាលទី៥ ហើយ។ នៅក្នុងការអនុវត្តគម្រោងដំណាក់កាលទី៥ នេះ យើងបានផ្ដោតសំខាន់ទៅលើការតាក់តែងបទប្បញ្ញត្តិគតិយុត្តដែលពាក់ព័ន្ធទៅនឹងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ការតាក់តែងទម្រង់គំរូដើម្បីសម្រួលដល់អ្នកអនុវត្តច្បាប់ប្រើប្រាស់ និងការដាក់បង្ហាញសេចក្ដីសម្រេចរបស់តុលាការ ដើម្បីឱ្យសាធារណជននៅទូទាំងប្រទេសអាចស្វែងយល់ទៅលើសេចក្ដីសម្រេចរបស់តុលាការ។

អស់រយៈកាលកន្លងមកនេះ គម្រោងបានធ្វើការផ្សព្វផ្សាយសេចក្ដីសម្រេចរបស់តុលាការ ទាក់ទងវិស័យរដ្ឋប្បវេណីនេះ បានចំនួន៦៤ ហើយ។ សកម្មភាពនៃការអនុវត្តគម្រោងដំណាក់កាលទី៥ នេះ ក៏ជាការឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងរបស់ប្រទេសកម្ពុជាផងដែរ។

បើគិតមកទល់បច្ចុប្បន្ន ដោយគិតចាប់ពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ មកគឺជាខួបគម្រប់១០ឆ្នាំហើយនៃការអនុវត្តក្រមរដ្ឋប្បវេណី។

ជារួម ចាប់ពីដំណើរការចាប់ផ្ដើមនៃការតាក់តែងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី រហូតដល់ការអនុវត្តនៃគម្រោងដំណាក់កាលទី៥នេះ បានឆ្លុះបញ្ចាំងអំពីភាពជោគជ័យយ៉ាងរឹងមាំនៃកិច្ចសហប្រតិបត្តិការនៅក្នុងការអភិវឌ្ឍវិស័យរដ្ឋប្បវេណីនៅក្នុងប្រទេសកម្ពុជាយើង៕ ■





ក្រមរដ្ឋប្បវេណីត្រូវបានអនុម័តនៅឆ្នាំ ២០០៧ និងក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានអនុម័តនៅឆ្នាំ២០០៦ ដែលបានដើរតួយ៉ាងសំខាន់នៅក្នុងការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណី។

# JTI វិនិយោគលើអនាគតរយៈពេលវែងរបស់កម្ពុជា



បុគ្គលិកJTIរៀបចំកញ្ចប់ស្បៀងអាហារ ដើម្បីចែកជូនដល់គ្រួសារដែលខ្វះខាត ក្នុងអំឡុងពេលការរាត-ត្បាតជំងឺកូវីដ១៩នៅក្នុងសហគមន៍ កាលពីឆ្នាំ២០២១ នៅរាជធានីភ្នំពេញ។ រូបថត៖ នៅ ពិសិដ្ឋ/JTI




JTI គឺជាក្រុមហ៊ុនបារីលំដាប់ពិភពលោកឈានមុខ ដែលមានប្រតិបត្តិការនៅប្រទេសចំនួន ១៣០ រួមទាំងកម្ពុជា។ JTI គឺជាសមាជិករបស់បណ្តាញក្រុមហ៊ុន JT Group។ JTI នៅប្រទេសកម្ពុជា ត្រូវបានទទួលស្គាល់ និងផ្តល់ចំណាត់ថ្នាក់ដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាថា JTI ជាក្រុមហ៊ុនមួយក្នុងបណ្តាក្រុមហ៊ុនបង់ពន្ធច្រើនជាងគេប្រចាំប្រទេស ដោយបានចូលរួមចំណែកការអភិវឌ្ឍ និងសេចក្តីរីកចម្រើននៃសេដ្ឋកិច្ចជាតិកម្ពុជា។

JTI កម្ពុជា មិនត្រឹមតែជាអ្នកបង់ពន្ធច្រើនប៉ុណ្ណោះទេ ថែមទាំងជាក្រុមហ៊ុនដំបូងគេនៅកម្ពុជាដែលទទួលបានពានរង្វាន់និយោជកឆ្នើមកម្រិតពិភពលោក រយៈពេល២ឆ្នាំជាប់ៗគ្នា ពីវិទ្យាស្ថាន Top Employers នៅទីក្រុងអាំស្ទែរដាំ ប្រទេសហូឡង់។ ជាងនេះទៅទៀត JTI ក៏បានស្ថិតក្នុងចំណោមក្រុមហ៊ុនទី១លើសកលលោក ដែលទទួលបានការទទួលស្គាល់ដោយស្តង់ដាសមភាពពិភពលោក ពីស្ថាប័ន EY ដែលវាយតម្លៃលើការផ្តល់ឱកាសស្មើភាពគ្នា និងប្រាក់កម្រៃស្មើភាពគ្នា នៅកន្លែងធ្វើការ។ ជាក់ស្តែង ម្តាយឪពុកនៅ JTI មិនប្រកាន់និន្នាការភេទណាទេ អាចទទួលបានការឈប់សម្រាកចំនួន៥ ខែ ដោយទទួលបានប្រាក់ខែពេញ ដើម្បីថែទាំគ្រួសារ នៅពេលពួកគេមានបុត្រថ្មីទើបកើត។

ការវិនិយោគលើសហគមន៍ ក៏ជាអាទិភាពអាជីវកម្មសម្រាប់ JTI ផងដែរ។ ជាមួយនឹងបុគ្គលិកក្រុមហ៊ុនបានផ្តល់ការគាំទ្រដល់សហគមន៍ក្នុងអំឡុងពេលការរាតត្បាតជំងឺកូវីដ១៩ ក្នុងសហគមន៍ តាមរយៈការផ្តល់ជាកញ្ចប់អាហារជូនដល់គ្រួសារងាយរងគ្រោះ។ សំខាន់ជាងនេះទៅទៀត JTI ក៏ជួយដល់ជនពិការ ជនចាស់ជរា និងជនអនាថាផងដែរ ព្រមទាំងផ្តល់ជំនួយដល់សហគមន៍ដែលបានរងគ្រោះដោយសារគ្រោះទឹកជំនន់។ បន្ថែមពីលើនេះ ក្រុមហ៊ុន ក៏វិនិយោគលើនិរន្តរភាពបរិស្ថាន ដោយការអនុវត្តគម្រោងដាំដើមឈើ និងកែច្នៃសំរាមឡើងវិញជាមួយដៃគូរបស់ខ្លួន។

ក្នុងនាមជាក្រុមហ៊ុនជប៉ុនដែលគោរពច្បាប់យ៉ាងខ្ជាប់ខ្ជួន និងទទួលបានការគោរពកោតសរសើរ ដែលកំពុងមានប្រតិបត្តិការនៅកម្ពុជា JTI នឹងបន្តចូលរួមចំណែកក្នុងកិច្ចអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចជាតិនៃប្រទេសកម្ពុជា ក្នុងរយៈពេលជាច្រើនឆ្នាំបន្ថែមទៀត៕

